ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៣១២

ចុះថ្ងៃទី ២៦_០៦_២០០៨

សាលដីកា

លេខ : ១០៦ "ខ"

ចុះថ្ងៃទី ១០_០៨_០៩

**តាមនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១០-០៨-២០០៩ ដោយមានសមាសភាព ដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ: ៣១២ ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០០៨ ដែលមាន:

១- **ជនជាប់ចោទឈ្មោះ** [redacted] **សំណាង** ភេទប្រុស អាយុ ២៥ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើចំការ ទីលំនៅសព្វថ្ងៃ [redacted] ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ក្រៅឃុំ។

២- **ជនជាប់ចោទឈ្មោះ** [redacted] **សំរុល** ភេទប្រុស អាយុ ២០ឆ្នាំ ជាតិខ្មែរ មុខរបរជាងម៉ូតូ ទីលំនៅសព្វថ្ងៃ [redacted] ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ក្រៅឃុំ។

**ត្រូវជាប់ចោទពីបទ:** បង្កអគ្គីភ័យដោយចេតនា ប្រព្រឹត្តនៅភូមិអូរចំបក់ ឃុំគ្រាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី ២៨-១០-២០០៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៥៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

- **ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted]រ៉ុម ភេទស្រី អាយុ ៣៥ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើចំការ ទីលំនៅសព្វថ្ងៃ ក្រុមទី៤ ភូមិអូរចំបក់ ឃុំគ្រាំង ស្រុកកំរៀង ខេត្តបាត់ដំបង។

**ដំណើររឿងហេតុទូទៅ:**

តាមពាក្យបណ្តឹងចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted]រ៉ុម ប្តឹងពីឈ្មោះ [redacted] **សំណាង** និង [redacted] **សំរុល** ដែលបានដុតជង្រុកពោតខ្លួន កាលពីថ្ងៃ២៨ ខែតុលា ឆ្នាំ២០០៦ ម៉ោង១០យប់។ ជង្រុកនេះមានទំហំ ៧ម គុណ ៨ម ប្រក់ស័ង្កសី ជញ្ជាំងក្តារ ពម្លស់ផុតពីដីកន្លះម៉ែត្រ នៅក្នុងជង្រុកមានផ្ទុកពោតទាំងស្លឹកមិនទាន់ប្រឡេះគ្រាប់ ១៥តោន



ថ្លៃសម្តែងសុភាសៈ សាលាឧទ្ធរណ៍-មហាអយ្យការ (ទល់មុខព្រះបរមរាជវាំង ក្បែរវិទ្យាស្ថានក្រសួងយុត្តិធម៌)

Scanned by CamScanner

សណ្តែកបាយ ១តោន និងសម្ភារៈទាំងអស់ក្នុងជង្រុក រេះអស់សរុបទឹកប្រាក់ ២៥ម៉ឺនបាត។ ពេលដុតមានសាក្សី២នាក់ ឈ្មោះ [redacted] សារឿន និង [redacted] យឿន បានឃើញឈ្មោះ [redacted] សំណាង និងឈ្មោះ [redacted] សំអុល ជាអ្នកដុត ព្រោះសាក្សីទាំង២នាក់នោះ ស្នាក់នៅចំការរបស់ឈ្មោះ អាឃ ចម្ងាយពីចំការខ្លួនប្រហែល៤០ម ។

- បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ០៩ ជ ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ២០០៨ របស់តុលាការខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ:

១- ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សំអុល ភេទប្រុស អាយុ ១៩ឆ្នាំ ( មានសវតាជាតិ) និងឈ្មោះ [redacted] សំណាង ភេទប្រុស អាយុ ២១ឆ្នាំ ( មានសវតាជាតិ) កំណត់ដាក់ពន្ធនាគាររយៈពេល១( មួយ) ឆ្នាំ គិតពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ និងឃុំខ្លួនក្នុងពន្ធនាគារ ពីបទ បង្កអគ្គិភ័យដោយចេតនា ប្រព្រឹត្តនៅភូមិអូរចំបក់ ឃុំគ្រាង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៦ តាមមាត្រា ៥៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២- ទុកសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រ៉ុម ប្តឹងទៅតុលាការផ្នែករដ្ឋប្បវេណីទាមទារសំណង និងជម្ងឺចិត្តតាមក្រោយ នៅពេលមានសំអាងគ្រប់គ្រាន់អំពីការខូចខាតដែលបង្កឡើងដោយឈ្មោះ [redacted] សំអុល និងឈ្មោះ [redacted] សំណាង ។

៣- សាលក្រមនេះជំនុំជម្រះច ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រ៉ុម និងជនជាប់ចោទឈ្មោះ [redacted] សំអុល កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សំណាង នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៨ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៨ បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

- បានឃើញរបាយការណ៍រឿងចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០០៨ របស់ចៅក្រមសាលាឧទ្ធរណ៍ ។

- បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០០៨ របស់ឈ្មោះ [redacted] រ៉ុម ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ០៩ ជ ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ២០០៨ របស់តុលាការខេត្តបាត់ដំបង ត្រង់ចំណុចទី២នៃសេចក្តីសម្រេច ។

- បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០០៨ របស់ឈ្មោះ [redacted] សំអុល និងឈ្មោះ [redacted] សំណាង ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ០៩ ជ ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ២០០៨ របស់តុលាការខេត្តបាត់ដំបង ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

## <u>នាពេលសវនាការ</u>

ចៅក្រមអានរបាយការណ៍រឿង

ជនជាប់ចោទឈ្មោះ [redacted] សំណាង ឆ្លើយថា: ខ្លួនមិនបានបង្កអគ្គិភ័យទេ ពេលនោះម៉ោង៨ព្រឹក ខ្លួនទៅចំការសណ្តែកសៀង ម៉ោង៣រសៀល ទើបត្រឡប់មកផ្ទះវិញ ពេលទៅចំការជួបឈ្មោះ [redacted] យួន ចាំចំការនៅរោងរបស់គាត់ចម្ងាយ២០០ម៉ែត្រ ទៅ៣០០ម៉ែត្រ ពីចំការរបស់ខ្លួន។ សំណូមពរ សុំឱ្យខ្លួនរួចសំណង ព្រោះខ្លួនមិនបានបង្កទេ។

ជនជាប់ចោទឈ្មោះ [redacted] សំអុល ឆ្លើយថា: ខ្លួនមិនបានបង្កអគ្គិភ័យទេ។ សំណូមពរ សុំឱ្យខ្លួនបានរួចពីបទចោទប្រកាន់។



Scanned by CamScanner

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] រ៉ុម ឆ្លើយថា: មានសាក្សីឈ្មោះ [redacted] យឿន បានឃើញអ្នកទាំង២ដុតជង្រុកសណ្ដែកសៀងរបស់ខ្លួន និងសាក្សីជាច្រើនទៀត បានឃើញអ្នកទាំង២ ដុត។ សំណូមពរ សុំទាមទារសំណងចំនួន ២៥០.០០០បាត។

## សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

មានភស្តុតាង មានពិរុទ្ធភាពគ្រប់គ្រាន់ ពីបទ បង្កអគ្គីភ័យ ដោយសាក្សីដាក់បន្ទុកជាច្រើន បានឃើញ ដូច្នេះ គួរតម្កល់សាលក្រមព្រហ្មទណ្ឌរបស់តុលាការខេត្តបាត់ដំបង ទុកជាបានការ។

- ក្រោយពីបានស្ដាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់។

## សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា:

១- បណ្ដឹងឧទ្ធរណ៍លេខ៣៧ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៨ របស់ជនជាប់ចោទឈ្មោះ [redacted] សំណាង និង [redacted] សំអុល និងបណ្ដឹងឧទ្ធរណ៍លេខ៤៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៨ របស់ឈ្មោះ [redacted] រ៉ុម ជាដើមបណ្ដឹងរដ្ឋប្បវេណី ធ្វើឡើងនៅក្នុងកំណត់ច្បាប់។

២- ជនជាប់ចោទទាំង២នាក់ ឆ្លើយមានន័យប្រហាក់ប្រហែលគ្នាថា កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៦ វេលាម៉ោង ៧ព្រឹក ខ្លួនទាំង២នាក់បានទៅចំការ ឃើញកម្មករ៤នាក់ មិនស្គាល់ឈ្មោះ នៅក្រុមទី៦ បានទៅមុនខ្លួន។ ពេលបាយថ្ងៃត្រង់រួច សម្រាក១ម៉ោង ទើបចូលច្រូតវិញ ដល់ម៉ោង៣រសៀល ពួកកម្មករមកផ្ទះវិញ ខ្លួនទាំង២នាក់ក៏មកជាមួយដែរ បែកគ្នានៅក្រុមទី៦។ លុះដល់ម៉ោង៤ ឈ្មោះ [redacted] សំណាង ថា ខ្លួនទៅលេងបាល់នៅភូមិអូរគគីរ រយៈពេល១ម៉ោង [redacted] សំអុល ពុំមាននិយាយពីរយៈពេលនេះទេ។ ចំការខ្លួនទៅជាប់ជង្រុករបស់ [redacted] រ៉ុម ហើយថា ខ្លួនពុំបានដុតភ្លើងនៅខាងដីខ្លួនក្បែរជង្រុកជនរងគ្រោះទេ តែកម្មករមិនស្គាល់ឈ្មោះ បានប្រមូលសម្រាមដុតសត្វកណ្ដុប ដុតភ្នក់តូច រួចពន្លត់វិញ។

៣- តាមចម្លើយសាក្សីថា ជាធម្មតា ខ្លួនតែងឃើញប្រុសារ [redacted] សំណាង វិលត្រឡប់ពីចំការទៅផ្ទះវិញនៅម៉ោង៣ ឬម៉ោង៤ លើកលែងតែថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៦ នៅវេលាម៉ោង៦ល្ងាច ទៅហើយ បែរជាឃើញ [redacted] សំណាង និង [redacted] សំអុល កំពុងបង្កាត់ភ្លើងប្រមូលកំណាត់ឈើទំហំប៉ុនភ្លៅជាច្រើន ដុតពីលើអង្កត់អុសប្រហែល៣គីក ក្នុងដីរបស់វា មានគម្លាតពីជញ្ជាំងជង្រុកជនរងគ្រោះ [redacted] រ៉ុម ប្រហែល១ម៉ែត្រ។ ពេលនោះ ខ្លួនទៅទិញស្រា ដើរក្បែរព្រំដី [redacted] សំណាង (ជនជាប់ចោទ) ឯប្រពន្ធខ្លួនទៅបត់ជើងធំនៅក្បែរចំការ [redacted] រ៉ុម ក៏បានឃើញបងប្អូន២នាក់ [redacted] សំណាង និង [redacted] សំអុល អូសភ្លើងពីភ្នក់នោះ មកដុតនៅក្បែរជង្រុកជនរងគ្រោះចម្ងាយប្រហែលកន្លះម៉ែត្រ ពីជង្រុកជនរងគ្រោះប៉ុណ្ណោះ។ ពេលនោះជង្រុកមិនទាន់ឆេះទេ។ លុះដល់ម៉ោង១០យប់ ខ្លួនភ្ញាក់ពីដេក ស្រាប់តែឃើញភ្លើងឆេះពេញក្រពុំ ខ្លួននិងប្រពន្ធ ព្រមទាំងពួកកម្មករ៦នាក់ បានដើរទៅឈរមើលភ្លើងឆេះជង្រុក [redacted] រ៉ុម រហូតដល់ម៉ោង២យប់ ទើបភ្លើងស្ងប់។ ពួកខ្លួនសន្និដ្ឋានថា ពិតជាមានពាក់ព័ន្ធនឹងឈ្មោះ [redacted] សំណាង និង [redacted] សំអុល ប្រាកដ ព្រោះគ្មានអ្នកផ្សេងមកក្បែរទេ។



Scanned by CamScanner

៣-១- សាក្សីឈ្មោះ [redacted] ហៅ ថា កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៦ នៅវេលាម៉ោងប្រហែល ខ្ញុំបានឃើញ [redacted] សំណាង និង [redacted] សំរុល បង្កាត់ភ្លើងឆេះ ដែលមានគំនរស្មៅនៅចម្ងាយប្រហែលកន្លះម៉ែត្រ ពីជង្រុកស្រូវ។ ភ្លើងឆេះជង្រុក [redacted] រ៉ុម ពិតជាពាក់ព័ន្ធនឹង [redacted] សំណាង និង [redacted] សំរុល ជាអ្នកដុតពិតប្រាកដ ។

៤- មានពិរុទ្ធភាពលើជនជាប់ចោទពីបទ បង្ករអគ្គីភ័យដោយចេតនា ប្រព្រឹត្តនៅភូមិអូរធំបក់ ឃុំត្រែង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៦ តាមមាត្រា ៥៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៥- ដើមចោទទាមទារសំណងខូចខាត និងជម្ងឺចិត្តចំនួន ៤០.០០០.០០០រៀល សាលាឧទ្ធរណ៍គួរពិចារណា លើកលែងតែចំណុចទី២ ត្រូវបដិសេធចោល ហើយសម្រេចឡើងវិញថា បង្គាប់ឱ្យជនជាប់ចោទសងសំណងខូចខាត និង ជម្ងឺចិត្តចំនួន ៣៥.០០០.០០០រៀល (សាមសិបប្រាំលានរៀល) ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីអ្នកស្រី [redacted] រ៉ុម នៅពេល ដែលសាលដីកានេះចូលជាស្ថាពរ ក្រៅពីនេះរក្សាទុកនៅដដែល ។

៦- សាលក្រមព្រហ្មទណ្ឌលេខ ០៩ “ជ” ចុះថ្ងៃទី ២១ ខែមីនា ឆ្នាំ២០០៨ របស់សាលាដំបូងខេត្តបាត់ដំបង សម្រេចត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ លើកលែងតែចំណុចទី២ គួរបដិសេធចោល ហើយសម្រេចឡើងវិញ ដូចយល់ឃើញខាងលើ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- ក- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣៧ ចុះថ្ងៃទី ៣១-០៣-២០០៨ របស់ឈ្មោះ [redacted] សំណាង និង [redacted] សំរុល ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយ ផ្ទុយនឹងអង្គច្បាប់ ។

ខ- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៤៣ ចុះថ្ងៃទី ០៤-០៤-២០០៨ របស់អ្នកស្រី [redacted] រ៉ុម ជាដើមបណ្តឹង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០៩ “ជ” ចុះថ្ងៃទី ២១-០៣-២០០៨ របស់សាលា ដំបូងខេត្តបាត់ដំបង ទុកជាបានការ លើកលែងតែចំណុចទី២ ត្រូវបដិសេធចោល ហើយសម្រេចឡើងវិញថា បង្គាប់ឱ្យជនជាប់ចោទសងសំណង ខូចខាត និងជម្ងឺចិត្តជាប្រាក់ចំនួន ៣៥.០០០.០០០ (សាមសិបប្រាំលាន) រៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីអ្នកស្រី [redacted] រ៉ុម នៅពេលដែលសាលដីកានេះចូលជាស្ថាពរ ក្រៅពីនេះរក្សាទុកនៅដដែល ។

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ មេធាវី ដើមបណ្តឹង និងដើមបណ្តឹង ។

បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

ក្រឡាបញ្ជី — ហត្ថលេខា: [redacted]

ចៅក្រមប្រឹក្សា — ហត្ថលេខា: [redacted]

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ — ហត្ថលេខា: [redacted]

---

ចម្លងត្រឹមត្រូវ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
[redacted] 403

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ . ថ្ងៃទី០៧ ខែ ១២ ឆ្នាំ២០០៨
ក្រឡាបញ្ជី

Scanned by CamScanner